ករុណា ការប្ដេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យកាល់ម៉ែត

## Calmette's Newsletter Nº 06

ខែ មេសា ២០១៨ - មិថុនា ២០១៨

ព្រឹត្តិបត្រលេខ ៦




រៀបចំដោយ

គណៈកម្មការទស្សនាវដ្ដីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ មេសា ២០១៨ - មិថុនា ២០១៨ ទស្សនាវដ្ដីលេខ ៦


០១ ការជួបជុំបណ្ដាញមន្ទីរពេទ្យ **និយាយភាសាបារាំង** នៅអាស៊ីអាគ្នេយ៍

០២ ទិវាវេជ្ជសាស្ត្រ-សល្យសាស្ត្រ លើកទី ២០ របស់មន្ទីរពេទ្យកាល់ម៉ែត!

០៣ សូមមេត្តាកុំមើលរំលងការរាករូសរ៉ាំរ៉ៃ វាអាចជាផលរំខានក្នុងជីវិតរស់នៅប្រចាំថ្ងៃ!

០៤ វិធីសាស្ត្របឋមដើម្បីបង្ការ និងព្យាបាល ជំងឺគ្រុនផ្ដាសាយ!

០៥ **ជំងឺមហារីកក្រពះ!**

០៦ ការមានផ្ទៃពោះលើសខែ ក៏ជាសញ្ញាគ្រោះថ្នាក់ចំពោះអ្នកម្ដាយ!

០៧ តើការធ្លាក់ឈាមស្រស់ៗនៅពេលបន្ទោរបង់លាមក **សុទ្ធតែជាជំងឺឬសដូងបាតឬ?**

០៨ កែវ ពីទារកកម្សត់ទៅជាកុមារាហាំមួនម្នាក់

០៩ សំណួរចម្លើយ Quiz? ទាក់ទងនឹងសុខភាព




# ការជួបជុំបណ្ដាញមន្ទីរពេទ្យ
# និយាយភាសាបារាំងនៅអាស៊ីអាគ្នេយ៍







តាមរយៈសិក្ខាសាលាស្ដីអំពី "ការគ្រប់គ្រងជារដ្ឋបាលផ្នែកបច្ចេកទេសវេជ្ជសាស្ត្រ និងការរៀបចំគ្រប់គ្រងជាសំណុំប៉ូល" និងការចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាង ក្រុមបណ្ដាញមន្ទីរពេទ្យក្រុងម៉ាកសី ប្រទេសបារាំង និង បណ្ដាញមន្ទីរពេទ្យនិយាយភាសាបារាំងនៅអាស៊ីអាគ្នេយ៍! Réseau Hospitalier Francophone d´Asie du Sud Est : La gouvernance médico-administrative et l´organisation en pôles!

ក្នុងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់សមត្ថភាពជំនាញ ប្រសិទ្ធភាព និងគុណភាពកម្រិតស្តង់ដាសាកល អំពីភាពជាអ្នកដឹកនាំគ្រប់គ្រងមន្ទីរពេទ្យ បណ្ដាញមន្ទីរពេទ្យនិយាយភាសាបារាំងនៅអាស៊ីអាគ្នេយ៍ (REHASE, Réseau hospitalier francophone d´Asie du Sud-Est)បានរៀបចំឲ្យមានជាថ្មីម្ដងទៀត នូវការជួបជុំកម្រិតថ្នាក់ដឹកនាំគ្រប់គ្រងមន្ទីរពេទ្យថ្នាក់តំបន់ និងអន្តរជាតិ នាថ្ងៃអង្គារ ១០ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធស័ក ពស២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមេសាឆ្នាំ២០១៨ នៅមន្ទីរពេទ្យកាល់ម៉ែតនៃកម្ពុជា តាមរយៈសិក្ខាសាលាស្វែងយល់គ្នាមួយ និងការចុះហត្ថលេខាអនុស្សរណៈបន្តកិច្ចសហប្រតិបត្តិការនា ឆ្នាំបន្តបន្ទាប់ ខាងមុខ។











សិក្ខាកាមចូលរួមដែលមកពីបណ្ដាមន្ទីរពេទ្យជាតិ និងខេត្តនៃព្រះរាជាណាចក្រកម្ពុជា បណ្ដាមន្ទីរពេទ្យជាតិនិងខេត្តនៃប្រទេសវៀតណាម និងឡាវ និងប្រទេសបារាំងបានជជែកពិភាក្សាលើប្រធានបទខាងលើ តាមរយៈការបង្ហាញពីប្រទេសនិមួយៗ និងចូលរួមដឹកនាំចែករំលែកបទពិសោធន៍ដោយអ្នកជំនាញការដឹកនាំគ្រប់គ្រងវិស័យមន្ទីរពេទ្យលោកស្រី សីលវីយា ប្ញតុង អគ្គនាយករងក្រុមបណ្ដាញមន្ទីរពេទ្យក្រុងម៉ាកសី ប្រទេសបារាំង។









# ទិវាវេជ្ជសាស្ត្រ-សល្យសាស្ត្រលើកទី ២០ របស់មន្ទីរពេទ្យកាល់ម៉ែត!

## 20ème Colloque Médico-chirurgical de l'hôpital Calmette!









ការជួបជុំវិទ្យាសាស្ត្រ អន្តរមន្ទីរពេទ្យទាំងថ្នាក់ជាតិ និងខេត្ត (Rencontre scientique interhospitalière) ដែលបានរៀបចំឡើងនាថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨ នៅមន្ទីរពេទ្យកាល់ម៉ែត បានផ្តល់ឱកាសដ៏មានសារសំខាន់ដល់គ្រប់គ្រូពេទ្យឯកទេស និងជំនាញ ផ្នែកវេជ្ជសាស្ត្រ-សល្យសាស្ត្រ ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក អំពីវិធីសាស្ត្រថៃទាំ និងព្យាបាលអ្នកជំងឺ ដោយផ្តោតលើសំណុំប្រធានបទធំៗ ៨គឺ៖

១- ការធ្វើរោគវិនិច្ឆ័យ និងវិធីសាស្ត្រព្យាបាលតាមបែបបច្ចេកវិទ្យាវេជ្ជសាស្ត្រ-សល្យសាស្ត្រទំនើប ប្រកបដោយប្រសិទ្ធភាព គុណភាពខ្ពស់ នៃវេជ្ជសាស្ត្រនុយក្លេអ៊ែ សម្រាប់ជំងឺ ពក ក (ក្រពេញមេអំបៅ ឬក្រពេញទីរ៉ូអ៊ីត) ដែលដាក់ឲ្យដំណើរការថ្មីៗនៅមន្ទីរពេទ្យកាល់ម៉ែតនៃព្រះរាជាណាចក្រកម្ពុជា។
២- ការធ្វើរោគវិនិច្ឆ័យ និងវិធីសាស្ត្រព្យាបាលជំងឺមហារីកច្រមុះ បំពង់ក
៣- វិធីសាស្ត្រដាក់ថ្នាំសណ្តំថ្មីៗសម្រាប់ការជំរុញឲ្យបានកាន់តែប្រសើរ ប្រសិទ្ធភាព និងគុណភាព កិច្ចការវះកាត់ ដុំមហារីកពោះវៀន។
៤- ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលប្រកបដោយប្រសិទ្ធភាពតាមរយៈការវះកាត់ ដុំក្រពេញអង់ដូគ្រីន ដែលជាមូលហេតុនៃការលើសសម្ពាធឈាមខ្លាំងក្លា ពិបាកគ្រប់គ្រង។
៥- ការព្យាបាលសង្គ្រោះបន្ទាន់អាយុជីវិតអ្នកជំងឺខ្សោយបេះដូង។
៦- ការធ្វើរោគវិនិច្ឆ័យ និងវិធីសាស្ត្រព្យាបាលសង្គ្រោះអាយុជីវិតក្នុងស្ថានភាពបន្ទាន់នៃជំងឺប៉ះពាល់សរសៃឈាមខួរក្បាល។
៧- វិធីសាស្ត្រព្យាបាលទំនើបថ្មីៗនៃជំងឺប្រព័ន្ធផ្លូវរំលាយអាហារ ពិសេសប្រព័ន្ធថង់ទឹកប្រមាត់។
៨- ការវះកាត់បន្ទាន់ជួយសង្គ្រោះសរសៃឈាមបេះដូងស្ទះ។

# សូមមេត្តាកុំមើលរំលងការរាករូសរ៉ាំរ៉ៃវាអាចជាផលរំខានក្នុងជីវិតរស់នៅប្រចាំថ្ងៃ!

ការរាករ៉ាំរ៉ៃ អាចជាបញ្ហាក្នុងចំណោមបញ្ហាជាច្រើន ដែលក្រុមវេជ្ជបណ្ឌិតឯកទេសផ្នែក ថ្លើម ក្រពះ ពោះវៀន និងឫសដូងបាតនៃមន្ទីរពេទ្យកាល់ម៉ែតតែងតែបានជួបប្រទះជាញឹកញាប់។ និយមន័យពិតប្រាកដនៃការរាករ៉ាំរ៉ៃនេះគឺជាការរាកដោយលាមកមានសភាពជ្រាយ (Semi liquide) ឬក៏ទឹកសុទ្ធ (liquide) ដែលមានរយៈពេលលើសពី២១ថ្ងៃឡើងទៅ។




**ក) មូលហេតុ**

កត្តាបង្កឲ្យមានការរាករ៉ាំរ៉ៃគឺមានច្រើន
ហើយពេលខ្លះគឺតម្រូវឲ្យមានការពិនិត្យ និងតាមដានដោយយកចិត្តទុកដាក់ក៏ដូចជាបច្ចេកទេសវេជ្ជសាស្ត្រលក្ខណៈឯកទេសផងដែរដូចជាៈ

- ជំងឺរលាកពោះវៀនធំដោយមេរោគឆ្លង (colite infectieuse) ក្នុងនោះក៏មានជំងឺរបេងពោះវៀនធំផងដែរ
- ជំងឺរលាកពោះវៀនធំដោយគ្មានមេរោគឆ្លង (colite inflamatoire)
- ជំងឺខ្សោយពោះវៀន ឬពោះវៀនដើរខុសធម្មតា (troubles fonctionnels intestinaux)
- មានដុំសាច់ដុះនៅក្នុងពោះវៀនធំ (មហារីកពោះវៀនធំ)
- ជំងឺឡើងជាតិពុលនៃក្រពេញចំពង់ក (hyperthyroidie)
- ជំងឺរាកនៅលើអ្នកជំងឺអេដស៍ ដែលភាគច្រើនជាងគេនោះគឺបង្កឡើងដោយពពួកផ្សិតនៅពោះវៀនធំ
- ពពួកប៉ារ៉ាស៊ីត (ព្រូន តេនញ៉ា អាមីប ជាដើម។ល។)
- វាក៏អាចបណ្តាលមកពីការពិសាឱសថមួយចំនួនផងដែរ (ជាពិសេសប្រភេទថ្នាំព្យាបាលជំងឺទឹកនោមផ្អែម។ល។)

**ខ) រោគសញ្ញា**

រោគសញ្ញាដែលអាចមានអមមកជាមួយការរាករូសរ៉ាំរ៉ៃមានៈ

- ក្តៅខ្លួន រងាញាក់
- ឈឺចុកចាប់ក្នុងពោះ
- លាមកមានលាយឈាម សំបោរ ឬខ្ទុះ
- ស្រកទម្ងន់លឿន និងខុសពីធម្មតា
- អស់កម្លាំង ល្ហិតល្ហៃ
- ស្លេកស្លាំង ចុះឬបាត់គ្រាប់ឈាមក្រហម
- មានដុំពោះ ដែលយើងអាចស្ទាបទៅប៉ះ
- ការខ្វះ ឬខ្សោះជាតិទឹក គឺយើងកម្រនឹងកើតមានណាស់ចំពោះការរាករូសរ៉ាំរ៉ៃនេះ។ល។

**គ) ការធ្វើរោគវិនិច្ឆ័យ**

ការរាករ៉ាំរ៉ៃ យើងអាចធ្វើរោគវិនិច្ឆ័យតាមរយៈ៖

- ការសាកសួរដោយលំអិតអំពីប្រវត្តជំងឺ និងរោគសញ្ញាផ្សេងៗដែលអមជាមួយជំងឺ
- ការពិនិត្យឈាម និងលាមក
- ការពិនិត្យអេកូពោះ ឬក៏ការថតស្កេនពោះ (CT-Scan)
- ការបណ្តុះមេរោគក្នុងលាមក (coproculture)
- ការឆ្លុះសុងមើលពោះវៀនធំ និងការវិភាគកោសិការបស់ពោះវៀនធំ (Coloscopie totale avec biopsie et anapath) គឺជាវិធីតែមួយគាត់សំរាប់ធ្វើរោគវិនិច្ឆ័យបានយ៉ាងល្អប្រសើរ ចំពោះករណីរាករ៉ាំរ៉ៃនេះ។

ឃ) ការព្យាបាល

ចូលចងចាំដែរថា ការរាករូសរ៉ាំរ៉ៃនេះវាមិនមែនជាជំងឺនោះទេ វាគឺជារោគសញ្ញាដែលបង្កឡើងដោយជំងឺ និងមូលហេតុដូចដែលបានជម្រាបជូនពីខាងលើ។
ដូច្នេះហើយចំពោះការព្យាបាលគឺតម្រូវឲ្យយើងដឹងមូលហេតុពិតប្រាកដថាមកពីអ្វី ហើយការព្យាបាលឲ្យចំមូលហេតុទាំងនោះហើយ ទើបជាការព្យាបាលត្រឹមត្រូវតាមបច្ចេកទេស និងមានប្រសិទ្ធភាពខ្ពស់បំផុត។

«យើងខ្ញុំជាក្រុមវេជ្ជបណ្ឌិតឯកទេស ផ្នែកជំងឺ ថ្លើម ក្រពះ ពោះវៀន និងឫសដូងបាតនៃមន្ទីរពេទ្យកាល់ម៉ែត រង់ចាំទទួលស្វាគមន៍ ក្នុងការពិនិត្យពិគ្រោះ និងផ្តល់ប្រឹក្សា ដើម្បីឈានទៅរកការព្យាបាល ទៅតាមស្ថានភាពជាក់ស្តែងនៃជំងឺ សំដៅ សុវត្ថិភាព ប្រសិទ្ធភាព និងគុណភាពនៃជីវិត។»





# វិធីសាស្ត្របឋមដើម្បីបង្ការ និងព្យាបាល ជំងឺគ្រុនផ្ដាសាយ!



**១) អ្វីទៅជាជំងឺគ្រុនផ្ដាសាយ ?**
ជាជំងឺដែលបង្កឡើងដោយ វីរុស(Virus) ឬAllegie។ ភាគច្រើនជំងឺនេះច្រើនកើតឡើងនៅរដូវវស្សា និងរដូវលំហើយ។

**២) ការចម្លងមេរោគ÷**
ជំងឺផ្ដាសាយឆ្លងតាមរយៈ
- ការក្អក
- កណ្ដាស់
- សំបោរ ស្លេស្ម
- នៅក្បែរអ្នកជំងឺផ្ដាសាយ ឬប៉ះវត្ថុដែលមានមេរោគ

**៣) រោគសញ្ញា÷**
អាការៈទូទៅនៃជំងឺគ្រុនផ្ដាសាយមាន:
- ចាប់ផ្ដើមឈឺគ្រុនក្ដៅភ្លាមៗ
- អស់កម្លាំង ខ្សោយ ល្វិតល្វៃ
- ឈឺខ្លួន ឈឺក ឈឺក្បាល រងា ញាក់
- ក្អកហៀរសំបោរ ។ល។

**៤) វិធីបង្ការ÷**
ដើម្បីបង្ការកុំឲ្យឆ្លងជំងឺគ្រុនផ្ដាសាយយើងត្រូវអនុវត្ត:
- ចាក់ថ្នាំបង្ការជំងឺគ្រុនផ្ដាសាយរៀងរាល់១ឆ្នាំម្ដង។
- ខ្ទប់មាត់របស់អ្នកដោយប្រើក្រដាស ឬកន្សែងនៅពេលក្អក ឬកណ្ដាស់ ឬខ្ទប់មាត់ដោយដៃរបស់អ្នក
- លាងដៃឲ្យបានស្អាត
- សម្អាតសម្ភារៈប្រើប្រាស់ឲ្យបានស្អាត
- ពាក់ម៉ាស់ឲ្យបានត្រឹមត្រូវ ។

៥) វិធីសាស្ត្របឋមដើម្បីព្យាបាលជំងឺគ្រុនផ្ដាសាយមាន៖
ក. វិធីព្យាបាលតាមបែបធម្មជាតិ:
- សម្រាកឲ្យបានគ្រប់គ្រាន់ និងមានខ្យល់អាកាសបរិសុទ្ធ
- ផឹកទឹកឲ្យបានច្រើន
- វិធីទី ១ ហាន់ខ្ញីជាចំណិតៗតូចៗហើយលាយជាមួយទឹកក្ដៅផឹករាល់ថ្ងៃ។
- វិធីទី ២ លាយទឹកឃ្មុំ ២ស្លាបព្រាកាហ្វេ និងទឹកក្រូចឆ្មា១ស្លាបព្រាកាហ្វេ រួចយកទៅលាយជាមួយទឹកក្ដៅមួយកែវតូចល្មមដើម្បីផឹករាល់ថ្ងៃ។



ខ. វិធីព្យាបាលដោយប្រើប្រាស់ឱសថដែលអាចប្រើប្រាស់បាននៅក្នុងគេហដ្ឋាន:
- បើមានអាការៈឈឺក្បាល ឬគ្រុនក្ដៅ៖ ប្រើឱសថប៉ារ៉ាសេតាម៉ុល មិនឲ្យលើសពី ៣ក្រាមក្នុងមួយថ្ងៃ (ចំពោះមនុស្សធំ) ឬមិនឲ្យលើសពី ៦០មីលីក្រាមក្នុង ១គីឡូ (ចំពោះក្មេង)។
- ករណីមានអាការៈ ផ្ដាសាយហៀរសំបោរបន្ថែម៖ គួរប្រើឱសថ ប្រូមេតាស៊ីន បន្ថែម ២ ទៅ ៤ដងក្នុង១ថ្ងៃ មិនឲ្យលើសពី ១៥០មីលីក្រាមក្នុង១ថ្ងៃ (ចំពោះមនុស្សធំ) ឬTamiflu ចំនួន៧៥មីលីក្រាម ២ដងក្នុងមួយថ្ងៃ (រយៈពេល៥ថ្ងៃ)។







បើមានរោគសញ្ញាណាមួយកើតឡើងដូចជា ឈឺបំពង់ក ឈឺច្រមុះ និងក្ដៅខ្លួនខ្លាំងលើសពី៣៨អង្សាសេ អ្នកជំងឺគួរស្វែងរកសេវាពិនិត្យពិគ្រោះយោបល់ជាមួយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យកាល់ម៉ែតដើម្បីទទួលបានការពិនិត្យ និងព្យាបាលត្រឹមត្រូវ និងជៀសវាងការផ្សំថ្នាំលេបដោយគ្មានវេជ្ជបញ្ជាត្រឹមត្រូវ ដែលអាចនាំឲ្យប៉ះពាល់ដល់សុខភាពលោកអ្នក។




# ជំងឺមហារីកក្រពះ !

មហារីកក្រពះកើតឡើងនៅពេលដែលកោសិកានៃជញ្ជាំង ក្រពះរីកលូតលាស់មិនឈប់ ក្រោមទម្រង់កាចសាហាវ។

**ក) មូលហេតុឲ្យពិតប្រាកដនៃជំងឺនេះ គឺមិនទាន់ដឹងនៅឡើយទេ កត្តាបង្ក នៃជំងឺនេះមានដូចជា៖**

- មានមេរោគក្រពះ Infection à helicobacter Pylori
- កត្តាចំណីអាហារ ចំណីអាហារប្រៃ, ចំណីអាហារផ្អាប់ និងមានផ្សែង
- មានគ្រួសារកើតជំងឺមហារីក
- ជក់បារី និងពិសាស្រា

**ខ) រោគសញ្ញានៃជំងឺកាចសាហាវនេះគឺ ៖**

- ឈឺចុងដង្ហើម, ឆ្អល់ពោះ
- អត់រំលាយអាហារ
- ស្រកទំងន់ ឬមិនឃ្លានអាហារ
- លាមកខ្មៅ
- ចង្អោរ និងក្អួត
- ស្លេកស្លាំង

**គ) ដើម្បីដឹងថាអ្នកជំងឺកើតជំងឺមហារីកក្រពះយើងត្រូវ៖**

- ធ្វើការឆ្លុះក្រពះ និងច្រឹបសាច់យកទៅពិនិត្យ។

ឃ) ជំងឺមហារីកក្រពះ ត្រូវបានព្យាបាលដោយ ៖

- ការវះកាត់
- ការចាក់ថ្នាំគីមី

**ង) យើងអាចការពារជំងឺមហារីកក្រពះបានដោយ៖**

- ពិសាសាប ចៀសវាងចំណីអាហារកំប៉ុង ឬផ្អាប់
- ពិសាផ្លែឈើស្រស់ និងបន្លែទៀតទាត់
- រក្សាទំងន់ដោយការហាត់ប្រាណ
- ចៀសវាងជក់បារី និង ពីសារស្រា

ជំងឺមហារីកក្រពះ អាចព្យាបាលជាសះស្បើយ បើយើងរកឃើញវាទាន់ពេលវេលា។

សូមពិគ្រោះ និងព្យាបាលជំងឺជាមួយគ្រូពេទ្យឯកទេសនៅមន្ទីរពេទ្យកាល់ម៉ែត ដើម្បីរក្សាសុខភាពលោកអ្នក ឲ្យបានរឹងមាំសម្រាប់គ្រួសារអ្នក មិត្តភក្តិអ្នក ព្រមទាំងមនុស្សជាទីស្រឡាញ់របស់អ្នក និងសង្គមជាតិទាំងមូល។










# ការមានផ្ទៃពោះលើសខែ ក៏ជាសញ្ញាគ្រោះថ្នាក់ចំពោះអ្នកម្តាយ!



ជាទូទៅស្រ្តីដែលមានផ្ទៃពោះគ្រប់ខែ គឺត្រូវធ្វើការសម្រាលបុត្រនៅគភ៌មានអាយុចន្លោះពី ៣៧ ទៅ ៤០សប្តាហ៍។ ក្នុងករណីស្រ្តីមានផ្ទៃពោះដែលធ្វើការសម្រាលបុត្រលើសពីអាយុ ៤១សប្តាហ៍ឡើងទៅ នោះគេហៅថាផ្ទៃពោះលើសខែ។ ការមានផ្ទៃពោះលើសខែនេះ គឺមិនត្រឹមតែមានគ្រោះថ្នាក់សម្រាប់ទារកនោះទេ អ្នកម្តាយក៏នឹងអាចប្រឈមនឹងគ្រោះថ្នាក់ផងដែរ។

**ក) ផលវិបាក៖**

សម្រាប់ស្រ្តីជាម្តាយ អាចប្រឈមនឹង:

- ការវះកាត់យកកូនកាន់តែច្រើនឡើង
- ការដាច់រហែកទ្វារមាសកម្រិត ៣ និង ៤
- ការធ្លាក់ឈាមក្រោយសម្រាល
- មានជំងឺ Chorioamniotite
- ការបង្ករោគនៅក្នុងភ្នាសស្បូន (endométrite)



ចំណាំ៖ អ្នកម្តាយទាំងឡាយត្រូវចងចាំអំពីកាលបរិច្ឆេទនៃពេលសម្រាល ដែលកំណត់ដោយគ្រូពេទ្យជំនាញ និងទុកដាក់ឯកសារឲ្យបានត្រឹមត្រូវ។ ក្នុងករណីអ្នកម្តាយមានផ្ទៃពោះលើសខែ គួរគប្បីរួសរាន់មកជួបជាមួយគ្រូពេទ្យជំនាញសម្ភពនៃមន្ទីរពេទ្យកាល់ម៉ែត ដើម្បីធ្វើការពិនិត្យ និងតាមដានឲ្យបានត្រឹមត្រូវ ដែលអាចជៀសផុតពីគ្រោះថ្នាក់ដល់ម្តាយ និងទារកក្នុងផ្ទៃ។

**ខ) ការតាមដានអ្នកម្តាយមានផ្ទៃពោះលើសខែ៖**

- ត្រូវធ្វើការតាមដានផ្ទៃពោះឲ្យបានកាន់តែជាប់លាប់ ចាប់ពីអាយុគភ៌ ៤១សប្តាហ៍
- គួរធ្វើការតាមដាន ២-៣ដង ក្នុង១សប្តាហ៍
- វិធីសាស្រ្តក្នុងការធ្វើការតាមដាន៖
  - ការថយចុះនៅចលនាបម្រាសរបស់កូនក្នុងពោះ ដែលធម្មតាស្រ្តីត្រូវការតាមដានក្នុងមួយថ្ងៃ (កូនត្រូវមានចលនាបម្រាសលើសពី ៣ដងក្នុងរយៈពេល ១ម៉ោង)។
  - ការធ្វើការវិភាគតាមរយៈ Monitoring នៅលើចង្វាក់បេះដូងកូន
  - ការធ្វើការវិភាគ Iformatisé du RCF
  - ការធ្វើអេកូសាស្រ្ត ដើម្បីស្វែងរកនៅការថយចុះបរិមាណទឹកភ្លោះដែលត្រូវធ្វើ ២ ទៅ ៣ដង ក្នុង១សប្តាហ៍ ចាប់ពីអាយុគភ៌៤១សប្តាហ៍ឡើងទៅ (ករណីមានការខ្វះទឹកភ្លោះ ត្រូវធ្វើការជំរុញឲ្យឈឺពោះសម្រាល និងបន្ថែមការតាមដាន)។





# តើការធ្លាក់ឈាមស្រស់ៗនៅពេលបន្ទោរបង់លាមក **សុទ្ធតែជាជំងឺឫសដូងបាតឬ?**

នៅក្នុងសង្គមយើងបច្ចុប្បន្ន ប្រជាពលរដ្ឋភាគច្រើននៅពេលដែលបន្ទោរបង់មក មានធ្លាក់ឈាមស្រស់តាមទ្វារលាមក តែងគិតថាវាជាជំងឺឫសដូងបាត។ បន្ទាប់មក អ្នកជំងឺបានចាប់យកការព្យាបាលជំងឺឫសដូងបាតតាមបែបមិនត្រឹមត្រូវ ដោយមិនបានធ្វើការពិគ្រោះ និងធ្វើរោគវិនិច្ឆ័យឲ្យបានច្បាស់លាស់ ជាមួយគ្រូពេទ្យឯកទេសដែលទាំងអស់នេះអាចនាំឲ្យខាតបង់ពេលវេលា ថវិកាមិនបានលទ្ធផល ព្រមទាំងអាចមានផលវិបាកធ្ងន់ធ្ងរថែមទៀត ពីព្រោះការធ្លាក់ឈាមស្រស់មានមូលហេតុច្រើនដូចជា៖

- ជំងឺឫសដូងបាត
- ជំងឺប្រេះទ្វារលាមក
- រលាកទ្វារលាមក
- ជំងឺមហារីកទ្វារលាមក ឬផ្នែកខាងចុងនៃពោះវៀនធំ។ល។




ដំបូន្មាន៖
រាល់មានការធ្លាក់ឈាមស្រស់នៅទ្វារលាមកពេលបន្ទោរបង់ សូមលោកអ្នកមកពិនិត្យ ពិគ្រោះ និងធ្វើរោគវិនិច្ឆ័យជាមួយវេជ្ជបណ្ឌិតជំនាញ ដើម្បីស្វែងរកមូលហេតុឲ្យបានច្បាស់លាស់ មុនឈានទៅរកការព្យាបាលចំទិសដៅ ព្រម ទាំងទទួលបានជោគជ័យខ្ពស់។

វេជ្ជបណ្ឌិតជំនាញឯកទេសនៃមន្ទីរពេទ្យកាល់ម៉ែត រង់ចាំផ្តល់ការប្រឹក្សា និង ដំបូន្មានល្អៗជូនលោកអ្នក។



ប្រេះ ឬ រហែកក្រសាលគូទ



ជាផលវិបាកនៃការព្យាបាលមិនត្រឹមត្រូវនេះប្រសិនបើអ្នកជំងឺបន្ទោរបង់មានធ្លាក់ឈាមស្រស់ដែលបណ្តាលមកពីជំងឺមហារីក តែអ្នកជំងឺបែរជាទទួលការព្យាបាលឫសដូងបាត ដែលខុសទិសដៅនោះ វានឹងធ្វើឲ្យយឺតពេលក្នុងការព្យាបាលជំងឺមហារីក។ ដូចនេះជំងឺមហារីកនឹងវិវត្តន៍ឬលូតលាស់ទៅរកដំណាក់កាលធ្ងន់ធ្ងរ ដែលពិបាកក្នុងការព្យាបាលឲ្យជាសះស្បើយ។





# កែវ ពីទារកកម្សត់ ទៅជាកុមារាមាំមួនម្នាក់









កែវពីទារកកម្សត់ ដែលរស់រានមានជីវិតក្រោមកិច្ចខិតខំរបស់ក្រុមគ្រូពេទ្យជំនាញទារក នៃមន្ទីរពេទ្យកាល់ម៉ែត ដោយមានការសហការជឿជាក់ និងផ្តល់កម្លាំងចិត្តអំពីក្រុមគ្រួសារ ព្រមទាំងខ្លួនកែវផង ដែលខំតស៊ូប្រឆាំងរហូតឈ្នះជាមួយបញ្ហាប្រឈមនឹងគ្រោះថ្នាក់អាយុជីវិតបន្ទាប់ពីសម្រាល។

ដោយទំនេរនឹងការប្រកបរបរទទួលទាន ថ្ងៃនេះឪពុកម្តាយរបស់កែវ បាននាំកែវមកលេងភ្នំពេញ ដោយពួកគាត់ត្រូវភ្ញាក់ពីព្រលឹមធ្វើដំណើរមកពីខេត្តរតនគីរីដោយរថយន្តឈ្នួល។ កាន់តែភ្ញាក់ផ្អើលនោះ ក្រុមគ្រួសារកែវបានឆ្លៀតពេលចូលមកលេងក្រុមគ្រូពេទ្យដែលបានសង្គ្រោះកែវ។ នៅពេលមកដល់ផ្នែកសង្គ្រោះទារក យើងបានឃើញអតីតទារកកម្សត់មួយនេះ មានដំណើរយ៉ាងរហ័ស រត់ផង ដើរផង ដោយក្តីក្លាហាន មើលទៅសុខភាពគាត់មាំមួនណាស់ ដែលមានកំពស់ ១១០ស.ម ទំងន់ ១១គីឡូក្រាម ប្រកបដោយភាពរហ័សរហួន ចេះនិយាយបានច្រើនឃ្លា ស្តាប់ និងសំលឹងមើលមុខគ្រូពេទ្យដោយក្លាហាន នេះបញ្ជាក់ថាគាត់មានសុខភាព ការលូតលាស់ប្រាជ្ញាស្មារតី និងកាយសម្បទាគឺបានល្អ។

ក្រុមគ្រូពេទ្យថែទាំ និងព្យាបាលទាំងអស់នៅផ្នែកសង្គ្រោះទារក សម្ភព និងបេះដូង ពិតជាមានសេចក្តីរីករាយឥតឧបមាចំពោះវត្តមានរបស់អូនកែវក្នុងថ្ងៃនេះ។ ដោយក្តីអាណិតស្រឡាញ់ និងការយកចិត្តទុកដាក់ពី ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត តាងនាមឲ្យថ្នាក់ដឹកនាំនៃមន្ទីរពេទ្យកាល់ម៉ែត និងក្រុមគ្រូពេទ្យ បានរៀបចំនូវវត្ថុអនុស្សាវរីយ៍ និងសម្ភារៈសិក្សាជាចំណងដៃជូនអូនកែវ និងជូនពរឲ្យកែវជាក្មេងពូកែ ឆ្លាត សុខភាពល្អ និងខិតខំរៀន ធ្វើយ៉ាងណាឲ្យក្លាយខ្លួនជាធនធានដ៏មានប្រយោជន៍ក្នុងការចូលរួមជួយអភិវឌ្ឍសង្គមជាតិយើង។







# សំណួរចម្លើយ Quiz?
# ទាក់ទងនឹងសុខភាព




**Q1. តើជំងឺរលៀកថ្លើមប្រភេទសេ ឆ្លងតាមរបៀបណា?**

១. ការប្រើចាន ឬ កែវ រួមគ្នា

២. តាមឈាម

៣. ចំណីអាហារ

៤. ការរួមភេទ



**Q2. ហេតុអ្វីបានជាពេលមានដំបៅជើង អ្នកជំងឺទឹកនោមផ្អែមត្រូវរួសរាន់មកមន្ទីរពេទ្យ?**

១. ដើម្បីកាត់បន្ថយគ្រោះថ្នាក់កាត់ជើង

២. ដើម្បីកាត់បន្ថយការក្លាយរោគ

៣. ដើម្បីកាត់បន្ថយរយៈពេលព្យាបាល

៤. ចម្លើយទាំងបីជាចម្លើយត្រឹមត្រូវ




**Q3. តើការប៉ះទង្គិចឆ្អឹងកងកមានរោគសញ្ញាដូចម្តេច?**

១. ឈឺជង្គង់ខ្លាំង

២. ឈឺកដៃ

៣. ឈឺកញ្ចឹងក

**Q4. ជំងឺគ្រុនឈាម ជាជំងឺឆ្លងតាមរយៈមូសខ្លាខ្វាំ ហើយជំងឺនេះ កើតទៅលើកុមារតែប៉ុណ្ណោះ។**

១. ពិត

២. មិនពិត






សូមមេត្តាផ្ទៀងផ្ទាត់ចម្លើយដែលផ្តល់ជូននៅព្រឹត្តិបត្រលេខបន្ទាប់



## ឧបត្ថម្ភដោយ


លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh
ហ្វេសប៊ុក: www.facebook.com/calmette.gov.kh



ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត